អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ ការព្យាបាលរោគផ្លូវចិត

website ៖ www.hoksavann.org

ថ្ងៃទី២១ វិច្ឆិកា ២០០៨



ព្រះពុទ្ធសំដែងថា រោគមានពីរប្រការគឺ រោគកើតផ្លូវកាយមួយ រោគកើតផ្លូវចិត្តមួយ ។

### អំពីរោគកើតផ្លូវកាយ

ព្រះពុទ្ធសាសនាបានចែងយ៉ាងច្បាស់ថា រូបរាងកាយរបស់មនុស្សសត្វ កើតអំពីធាតុទឹកដីភ្លើងខ្យល់ កើតឡើងស្ថិតនៅនិងទីបំផុតត្រូវរលាយទៅវិញ គឺកាលណាមានជាតិ តែងតែមានជរាព្យាធិ និងមរណៈ ។ តាមគម្ពីរព្រះអភិធម្មបញ្ជាក់ទៀតផង រូបរាងកាយរបស់មនុស្សសត្វគ្មានអ្វីក្រៅពីខន្ធប្រាំឡើយ គឺរូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ហើយខន្ធប្រាំនេះប្រព្រឹត្តទៅជាអនិច្ចំ ទុក្ខំ និងអនត្តា ។ ដូច្នេះបញ្ជាក់ថា កាលណាមានរូបតែងតែកើតមានជម្ងឺគ្រប់ជំពូក គ្រាន់តែកើតមានជម្ងឺតិចច្រើនជាងគ្នាប៉ុណ្ណោះ តាមអំពើកម្មផលរបស់ខ្លួន ។ ជីវិតរបស់មនុស្សសត្វទាំងឡាយ ដែលអាចរស់នៅបាន អាស្រ័យចំណីអាហារ ការដកដង្ហើមចេញចូល ធាតុអាកាសល្អ ឥរិយាបទប្រព្រឹត្តទៅស្មើគ្នា បើខ្វះកត្តាណាមួយ ជីវិតនឹងទទួលការលំបាករហូតបាត់បង់ជីវិត ។ ដូច្នេះជីវិតរស់នៅដោយលក្ខខណ្ឌបែបនេះ ជាជីវិតផុយស្រួយណាស់ ដូចពុទ្ធភាសិតថា កិច្ឆំ មច្ចាន ជីវិតំ ប្រែថា ជីវិតរបស់សត្វទាំងឡាយ រស់នៅដោយកម្រ ។

វិធីដោះស្រាយរោគផ្លូវកាយ ព្រះពុទ្ធបានណែនាំឲ្យមនុស្សប្រើថ្នាំសំរាប់ព្យាបាល ដូចព្រះបានអនុញ្ញាតដល់ភិក្ខុសង្ឃឲ្យប្រើថ្នាំនៅពេលមានជម្ងឺ ដែលហៅថាគិលានភេសជ្ជបច្ច័យ ។ ការព្យាបាលនេះ គឺជាការសម្រួលដល់ធាតុ ព្រោះរូប

រាងកាយជាធាតុ រីឯថ្នាំដែលយកមកព្យាបាលនោះ ក៏ជាធាតុ ។ ព្រះពុទ្ធសាសនាក៏បង្រៀនពុទ្ធសាសនិកជនឲ្យមានអនាម័យ គឺវិធីការពារកុំឲ្យមានរោគ ដើម្បីឲ្យជីវិតដែលជាអនត្តានេះរស់នៅបានយូរ ក្នុងបំណងធ្វើអំពើឲ្យបានច្រើនក្នុងការរំដោះទុក្ខ មានជាតិទុក្ខជាដើម ។ ដូចពុទ្ធភាសិតមួយបទពោលថា អរោគ្យា បរមា លាភា ប្រែថា ការមិនមានរោគជាលាភដ៏ប្រសើរ, ព្រះពុទ្ធបានប្រៀបរូបកាយរបស់មនុស្សសត្វ ដូចជាយន្តយានគ្រប់ប្រភេទ ដោយប្រើពាក្យថា សរីរយន្តំ ប្រែថា សរីរយន្ត យាបនីយំ ប្រែថា វាដើរទៅមុខ ឬប្រព្រឹត្តទៅមុខដូចបេះដូងដើរ សួតដកដង្ហើមចេញចូលជាដើម បើវាដើរមិនប្រក្រតី នឹងធ្វើឲ្យជីវិតអន្តរាយ ។

ពុទ្ធសាសនាក៏ទទួលស្គាល់តាមផ្លូវវេជ្ជសាស្ត្រថា ជម្ងឺបណ្តាលមកពីមេរោគធ្វើឲ្យខូចអង្គធាតុផ្នែកណាមួយនៃរូបរាងកាយ ហើយថ្នាំអាចព្យាបាលឲ្យជាបានបើថ្នាំនោះមានឥទ្ធិពលសម្លាប់មេរោគនោះបាន ។ សព្វថ្ងៃនេះ បច្ចេកវិទ្យាផ្នែកព្យាបាលជម្ងឺនេះមានការលូតលាស់ខ្លាំងណាស់ ។ ប៉ុន្តែទោះបីបានលូតលាស់យ៉ាងនេះក៏ដោយ ក៏ពុំអាចព្យាបាលឲ្យមនុស្សបាត់ឈឺរហូត និងផុតពីការចាស់និងស្លាប់បានឡើយ ។ ការព្យាបាលនេះ គ្រាន់តែពន្យាពេលស្លាប់ប៉ុណ្ណោះ ។ ដូច្នេះការចាស់ឈឺស្លាប់នេះផុតពីសមត្ថភាពរបស់វិទ្យាសាស្ត្រដែលអាចដោះស្រាយបាន ចំណែកព្រះពុទ្ធដោះស្រាយបាន គឺការបានសម្រេចព្រះនិព្វាន ដោយបាលីថា អមតំ និព្វានំ ប្រែថានិព្វានមិនស្លាប់ ។

ដូចបានពោលមកហើយ វិធីដោះស្រាយតាមផ្លូវព្រះពុទ្ធសាសនាពេលមនុស្សមានជម្ងឺ មិនឃើញព្រះពុទ្ធបង្រៀនឲ្យមនុស្សបន់ស្រន់បួងសួងអង្វរករឲ្យទេវតា ព្រះឥន្ទ្រ ព្រះព្រហ្ម ឬសុំឲ្យព្រះអង្គជួយឲ្យជារោគឡើយ ។ ជំនឿមនុស្សជំនាន់ដើម កាលណាបើមានភ័យគ្របសង្កត់ មានជម្ងឺដ៏កាត់បៀតបៀនជាដើម តែងតែបន់ស្រន់វត្ថុខាងក្រៅ ដែលយល់ថាអាចជួយខ្លួនបាន ។ សម័យក្រោយមក ដោយមានការជឿនលឿនខាងចំណេះដឹង ជំនឿបែបនេះបានត្រូវចុះខ្សោយ ពេលមានជម្ងឺបែរមករកថ្នាំ ឬនាំទៅពេទ្យឲ្យព្យាបាល ស្របតាមវិធីរបស់ព្រះពុទ្ធសាសនា ។ ព្រះពុទ្ធសាសនាសំដែងថា ផលអ្វីមួយកើតឡើង ព្រោះមានហេតុរបស់វា ដូចមនុស្សមានជម្ងឺ ព្រោះមានហេតុនាំឲ្យមានជម្ងឺ ដូចអាការៈ

ក្នុងខ្លួនដើមិនប្រក្រតីមកអំពីខួចផ្នែកណាមួយ ពុំមែនខ្មោចបិសាចធ្វើឲ្យឈឺឡើយ ហើយទេវតា ព្រះឥន្ទ ព្រះព្រហ្មក៏ពុំអាចធ្វើឲ្យបាត់ឈឺដែរ ។ វិធីដោះស្រាយជម្ងឺផ្លូវកាយតាមព្រះពុទ្ធសាសនា ស្របតាមវិទ្យាសាស្ត្រផ្នែកវេជ្ជសាស្ត្រ គឺផ្លូវប្រើថ្នាំព្យាបាល ហើយជម្ងឺខ្លះត្រូវវះកាត់ ។ បើព្យាបាលមិនជាបានន័យថាពេលវេលាកំណត់អាយុដែលត្រូវស្លាប់បានមកដល់ហើយ ស្របតាមកម្មផលរបស់ខ្លួនដែលបានសាងមក ពុំមែនជាព្រះព្រហ្មលិខិតលោកចារមកទេ ។ បើស្លាប់ដោយចាស់ជរា បានន័យថាជាទោសរបស់វដ្តសង្សារ ដែលអ្នកណាក៏ពុំអាចជៀសវាងបាន ទោះបីខ្លួនមានកុសលផលបុណ្យច្រើនយ៉ាងណាក៏ដោយ តួយ៉ាងដូចព្រះពុទ្ធ ព្រះអង្គមានបារមីដ៏ខ្ពស់ ក៏ត្រូវជរាញាំញីក្នុងព្រះកាយរបស់ព្រះអង្គ ក៏ត្រូវរំលត់ខន្ធបរិនិព្វានក្នុងព្រះជន្ម៨០ ។

(នៅមានត)

❄ ❄

❄